# ការណែនាំរបៀបរៀបចំខ្លួនដើម្បី ធ្វើសិហាំមួយ ដូស្គពីតែស្ស

(Flexible sigmoidoscopy)

ថ្ងៃណាត់ជួប : ______________________

ម៉ោងណាត់ជួប : ______________________

ទីកន្លែង : ______________________

ផ្អាកប្រើថ្នាំដូចខាងក្រោមនេះ :

- អាស្ពីរីន **ដប់ថ្ងៃមុនថ្ងៃណាត់ជួប**
- ថ្នាំបំបាត់ឈឺសន្លាក់ និងថ្នាំការពារហើមរលាក **ពីរថ្ងៃមុន ថ្ងៃណាត់ជួប** ។

ឧទាហរណ៍ ថ្នាំបំបាត់ឈឺសន្លាក់ ឬថ្នាំដែលមានជាតិអាស្ពីរីន មានដូចជា : នូព្រីន ប៊ូហ្វើរិន អាណាស៊ីន អាត់វៀល ម៉ូទ្រីន អ៊ីនដូស៊ីន វ៉ូលត្រាន អាលីវ និង អ៊ីកូទ្រីន ។ លោកអ្នកអាចប្រើថ្នាំថៃលិណុល ឬ អាស៊ីតាមីណូហ្វែន បាន ។

ប្រសិនបើលោកអ្នកលេបថ្នាំដូចខាងក្រោមនេះ សូមលេបបន្តទៀតតាមការណែនាំរបស់គ្រូពេទ្យ :

- **ថ្នាំសំរាប់ជម្ងឺបេះដូង**
- **ថ្នាំសំរួលការដកដង្ហើម**
- **ថ្នាំសំរាប់ជម្ងឺលើស ឬ ខ្វះឈាម**
- **ថ្នាំដ៏ទៃទៀត ដែលមានវេជ្ជបញ្ជា**

ការណែនាំពិសេសសំរាប់អ្នកជម្ងឺដែលលេបថ្នាំខ្វូម៉ាឌិន :

______________________

______________________

______________________

តាមធម្មតាអ្នកអាចពិសារម្ហូបអាហារមុនពេលទៅធ្វើសិហ្គមួយដូស្កូពីបាន ។ ជួនកាលគ្រូពេទ្យរបស់អ្នកអាចនឹងសុំឲ្យអ្នកពិសារអាហាររាវ ហើយឲ្យជៀសវាងអាហាររឹងចំនួនពីរឬបីម៉ោង មុនពេលណាត់ជួបនោះ។ចំណីអាហាររាវមានដូចជា: ទឹកក្រូចសូដា កាហ្វេ ទឹកតែ ចាហួយ ទឹកប៉ោម ទឹកទំពាំងបាយជូ ទឹកក្រាន់ប៊ែរី ទឹកស៊ុបសាច់គោ ឬសាច់មាន់ ហើយនិងស្ករគ្រាប់រឹង ។

ចំពោះការណាត់ជួបពេលព្រឹក:

១. **នៅពេលល្ងាចមុនពេលពិនិត្យរោគ** សូមបញ្ចូលទឹកហ្វ្លីតអិនីម៉ាមួយដប (one Fleets Enema) តាមរន្ធគូថដោយខ្លួនឯង និងដោយធ្វើតាមការណែនាំដែលមានភ្ជាប់ជាមួយនោះស្រាប់ ។

២. **នៅថ្ងៃពិនិត្យរោគ** សូមបញ្ចូលទឹកហ្វ្លីតអិនីម៉ាមួយដប (one Fleets Enema) តាមរន្ធគូថដោយខ្លួនឯង មួយម៉ោងមុនពេលចេញទៅមន្ទីរពិនិត្យរោគ ។

ចំពោះការណាត់ជួបពេលល្ងាច :

១. **នៅម៉ោងប្រហែល ៨:០០ព្រឹកនាថ្ងៃទៅពិនិត្យ** សូមបញ្ចូលទឹកហ្វ្លីតអិនីម៉ាមួយដប (one Fleets Enema) តាមរន្ធគូថដោយខ្លួនឯង ដោយធ្វើតាមការណែនាំដែលមានភ្ជាប់ជាមួយនោះស្រាប់ ។

២. **រយះពេលមួយម៉ោងមុនពេលណាត់ជួប** សូមបញ្ចូលទឹកហ្វ្លីតអិនីម៉ាមួយដប (one Fleets Enema) តាមរន្ធគូថដោយខ្លួនឯង មុនពេលចេញទៅមន្ទីពិនិត្យរោគ ។

ទឹកហ្វ្លីតអិនីម៉ា (Fleets Enema) អាចរកទិញបាននៅគ្រប់ឱសថដ្ឋាន ឬកន្លែងលក់ថ្នាំ ដោយមិនចាំបាច់មានសំបុត្រពីគ្រូពេទ្យឡើយ ។

បើមានសំនួរ? សូមទូរស័ព្ទ : ______________________